00665538

E9/25

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ ៖ សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន ៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម ៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ ៖ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន ៖

ឈ្មោះមន្ត្រីកត់ត្រា ៖

ហត្ថលេខា ៖

---

**បញ្ជីឯកសារបឋមលើកទីបីរបស់ អៀង សារី**

---

| <u>ដាក់ដោយ</u>៖ | <u>ផ្ញើជូន</u>៖ | <u>ផ្ញើជូន</u>៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
19 / 04 / 2011
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អនុលោមតាមដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យភាគីដាក់ឯកសារសម្រាប់រៀបចំសវនាការ ("ដីកាបង្គាប់")[1] លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះសូមដាក់បញ្ជីឯកសារបឋមលើកទីបី ដែលបង្ហាញនៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ("បញ្ជីឯកសារបឋមលើកទីបី") ដែលបញ្ជាក់ពីឯកសារថ្មីៗដែលមេធាវីការពារក្តីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ញត្តិនេះត្រូវធ្វើឡើងជាចាំបាច់ដើម្បីគោរពតាមដីកាបង្គាប់[2]។ អនុលោមទៅតាមដីកាបង្គាប់នេះ[3] និង នៅក្នុងករណីដែលអាចធ្វើទៅបាន ឯកសារនីមួយៗយោងទៅរកផ្នែកនៃសំណុំឯកសារផ្សេងទៀត (cross-reference) ទៅលើ"ចំនុចនៃការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ" ដែលបានកំណត់អត្តសញ្ញាណដោយការយោងទៅលើ "បញ្ជីនៃបញ្ហាដែលជាភស្តុតាង" ដែលបានផ្តល់ឱ្យភាគីដោយអង្គជំនុំជម្រះសាលាដំបូង។ ចំណាត់ថ្នាក់ទាំងនេះមានលក្ខណៈជាបណ្តោះអាសន្ន ដោយសារមេធាវីការពារក្តី នៅពេលនេះ មិនអាចធ្វើការវិភាគលំអិតទៅលើឯកសារទាំងអស់ដែលមាននៅក្នុងបញ្ជីឯកសារបឋមលើកទីបី ហើយសូមរក្សាសិទ្ធិដាក់បន្ថែម និង/ឬកែប្រែ "ចំនុចនៃការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ" នៅក្នុងជួរនៃបញ្ជីឯកសារបឋមលើកទីបី[4]។ បន្ថែមពីលើនេះ ដោយសារតែមិនមែនឯកសារទាំងអស់នៅក្នុងបញ្ជីឯកសារបឋមលើកទីបីបំពេញបាននូវលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃសម្រាប់ភាពអាចទទួលយកបាននៅ

---

[1] *ករណី នួន ជា* ០០២-១៩-០៩-២០០៧-អវតក/អជសដ ដីកាបង្គាប់ឱ្យភាគីដាក់ឯកសារដើម្បីត្រៀមរៀបចំសវនាការជំនុំជម្រះក្តី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ E9, ERN: 00635754-00635759 ។

[2] បញ្ជីឯកសារបឋមលើកទីបី ជាបញ្ជីឯកសារដែលមានលក្ខណៈលំអិត និងទូលំទូលាយ តាមដែលអាចធ្វើទៅបាននៅដំណាក់កាលនេះនៃដំណើរការនីតិវិធីដែលបានចុះបញ្ជីឯកសារនានាដែលទាក់ទងទាំងសាក្សីដែលមេធាវីការពារក្តីបានស្នើសុំ និងឯកសារពាក់ព័ន្ធនឹងករណីប្រឆាំងនឹងលោក អៀង សារី បើផ្អែកតាមសហឧក្រិដ្ឋកម្មរួមដែលបានចោទប្រកាន់នៅដីកាដំណោះស្រាយ ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/កសចស ដីកាដំណោះស្រាយចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ D427, ERN: 00604508-00605246, paras. 156-220 ។ សូមមើលផងដែរសារអ៊ីម៉ែលពី Susan Lamb មន្ត្រីច្បាប់នៅអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅភាគីទាំងអស់នៅក្នុងករណី០០២ ចុះថ្ងៃទី៨ ខែមេសាឆ្នាំ២០១១ ។

[3] ដីកាបង្គាប់ នៅកថាខណ្ឌទី ១២(iii) ។

[4] តាមទំហំនៃឯកសារពាក់ព័ន្ធ ថ្វីបើមានការខិតខំប្រឹងប្រែងរបស់ខ្លួនយ៉ាងណាក្តី មេធាវីការពារក្តីនៅមិនទាន់ធ្វើការវិភាគពេញលេញនៅឡើយលើឯកសារទាំងនោះដែលបានរាយបញ្ជី ដើម្បីពិចារណាថាពួកវាសមរម្យនិងអាចទទួលយកបានឬទេ។

អវតក[5] ទើបមេធាវីការពារក្ដីរក្សាសិទ្ធិជំទាស់នឹងឯកសារណា ដែលមាននៅក្នុងបញ្ជីដែលនឹងត្រូវដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[6]។ បញ្ជីឯកសារបឋមលើកទីបីមានដាក់បញ្ចូលនូវប្រភពបន្ទាប់បន្សំ

---

[5] សូមមើលវិធាន ៨៧(៣) ដែលចែងថា: អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្ដីសម្រេចរបស់ខ្លួនដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬ ប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី ។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬ ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមស្របនៅក្នុងសវនាការ ។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក) មិនជាប់ពាក់ព័ន្ធ ឬ ជាស្នើសុំជាន់គ្នា ខ) មិនអាចរកបានក្នុងរយៈសមស្របណាមួយ គ) មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំឱ្យពិនិត្យភស្តុតាង ឃ) ច្បាប់មិនអនុញ្ញាត ឬ ង) មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍" ។ បញ្ជីភស្តុតាងបឋមលើកទីបីមានឯកសារជាច្រើន ដែលបង្កើតឡើងដោយបុគ្គលជាច្រើនក្នុងនាមជាអ្នកជំនាញដែលស្នើឡើងដោយ កសព និង ដើមបណ្ដឹងរដ្ឋប្បវេណី ឧទាហរណ៍អត្ថបទនិពន្ធដោយលោក David Chandler ។ មេធាវីការពារក្ដីមិនទាន់ទទួលបានឯកសារដែលបង្កើតឡើងដោយបុគ្គលទាំងនេះទេ ។ ឧទាហរណ៍លោក David Chandler ត្រូវកោះហៅជាអ្នកជំនាញនៅក្នុងករណី ០០២ ។ សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អបសជ ការបដិសេធលើកដំបូងចំពោះសំណើសុំអ្នកជំនាញរបស់ កសព និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែម ។ នៅក្នុងរយៈពេល ៣០ ថ្ងៃ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ERN: 00647694 – 00647979, ។ សូមមើលឧបសម្ព័ន្ធ ។ សូមផងដែរ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អបសជ ការបដិសេធបឋមចំពោះសំណើសុំអ្នកជំនាញរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសំណើសុំការអនុញ្ញាតដើម្បីដាក់សារណានៅក្នុងរយៈពេល ៣០ ថ្ងៃ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ E9/4/3/1, ERN: 00647819 – 00647831 នៅកថាខណ្ឌទី២២ ។ សូមមើលផងដែរឧបសម្ព័ន្ធ ។ មេធាវីការពារក្ដីនឹងបដិសេធការផ្សព្វផ្សាយនិងសម្ភាសន៍របស់បុគ្គលទាំងនេះ ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ លុះត្រាណាតែអង្គជំនុំជម្រះសាលាដំបូងសម្រេចកោះហៅពួកគេធ្វើជាសាក្សី ។ មេធាវីការពាររក្សាសិទ្ធិយកមកសំអាងតាមករណីជាក់ស្ដែងទៅលើឯកសារដែលបង្កើតឡើងមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងប្រភពបន្ទាប់បន្សំដែលផ្អែកលើភស្តុតាងដែលផលិតដាមរយៈការធ្វើទារុណកម្ម បើសិនអង្គជំនុំជម្រះសាលាដំបូងសម្រេចថាឯកសារទាំងនេះអាចទទួលយកបាននោះ ។ សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អបសជ ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងញត្តិ E67, E57, E58, E23, E59, E20, E33, E71, និង E73 បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ E74, ERN: 00659301-00659304 នៅទំព័រទី៣ ។

[6] ចំនុចនេះសមស្របជាមួយការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូង ដូចដែលបានប្រកាសយ៉ាងច្បាស់នៅកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ។ សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អបសជ ការឆ្លើយតប

នៃសម្ភារៈទាំងអស់ដែលត្រូវបានចុះបញ្ជីរួមគ្នាជាមួយប្រភពចម្បងនៃសម្ភារៈទាំងអស់ ដែលត្រូវបានលើកមកសំអាងនៅក្នុងប្រភពបន្ទាប់បន្សំនោះ។ ដើម្បីរក្សាពេលវេលាឲ្យខ្លី និងដើម្បីជាប្រយោជន៍ដល់ការសន្សំសំចៃការចំណាយរបស់តុលាការ មេធាវីការពារក្តីសុំបញ្ចូលនិងដាក់បន្ថែមអង្គហេតុ និង ទឡ្ហីករណ៍នានាដែលបានចែងនៅក្នុងបញ្ជីឯកសារបឋមដែលមាននៅក្នុងសំណុំរឿងរួចហើយ & ការជូនដំណឹងអំពីបញ្ជីបឋមនៃឯកសារថ្មីៗរបស់គាត់ ដែលនឹងមកដល់ ដើម្បីដាក់ជូនអង្គជំនុំជម្រះនៅសវនាការ[7] និង បញ្ជីឯកសារបឋមលើកទីពីររបស់លោក អៀង សារី ដែលមាននៅក្នុងសំណុំរឿងរួចហើយ & ការជូនដំណឹងអំពីបញ្ជីបឋមនៃឯកសារថ្មីៗរបស់លោក អៀង សារី ដែលនឹងមកដល់ ត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះនាពេលសវនាការ[8]។ មិនមានអ្វីនៅក្នុងញត្តិនេះត្រូវបានបកស្រាយថាជាការលះបង់សិទ្ធិក្នុងការធ្វើសំណើសុំការពិចារណាដែលមាននៅក្នុងញត្តិនេះទេ មិនថាឡើយការរក្សាសិទ្ធិរបស់មេធាវីការពារក្តី ដើម្បីដាក់បន្ថែមបញ្ជីឯកសាររបស់ខ្លួននៅដំណាក់ក្រោយៗទៀត[9] ។

---

របស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងញត្តិ E67, E57, E58, E23, E59, E20, E33, E71, និង E73 បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ E74, ERN: 00659301-00659304 នៅទំព័រទី៣ ។

[7] សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អបសជ បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមាននៅក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងអំពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ E22/9, ERN: 00659454-00659459 (“បញ្ជីឯកសារបឋមរបស់ អៀង សារី”) ។

[8] សំណុំរឿង អៀង សារី ០០២-១៩-០៩-២០០៧/អជសជ បញ្ជីបឋមលើកទីពីររាយឯកសារនានារបស់ អៀង សារី មានរួចស្រេចក្នុងសំណុំរឿង & ការជូនដំណឹងពី បញ្ជីបឋមនឹងមកដល់រាយឯកសារថ្មីៗសម្រាប់ដាក់នៅចំពោះមុខអង្គជំនុំជម្រះនាពេលសវនាការ ៨ មេសា ២០១១ (“បញ្ជីបឋមលើកទីពីររាយឯកសារនានារបស់ អៀង សារី”)។

[9] សូមមើលបញ្ជីឯកសារបឋមរបស់ អៀង សារី នៅកថាខណ្ឌទី ៣០-៣៧ ។ បញ្ជីឯកសារបឋមលើកទីពីររបស់ អៀង សារី នៅកថាខណ្ឌទី ៦-៧ ។ មេធាវីការពារក្តីកត់សំគាល់ពីសារអេឡិត្រូនិចរបស់មន្ត្រីអ្នកច្បាប់របស់អង្គជំនុំជម្រះ ផ្ញើទៅភាគី ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ដែលអង្គជំនុំជម្រះសាលាដំបូងយោង “ភាគីចំពោះវិធាន ៨៧(៤) (ការសម្រេចលើការទទួលយកភស្តុតាងថ្មីនៅសវនាការ) និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនៅក្នុងករណី ០០១ (សូមមើលឧបទាហរណ៍ “សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃភស្តុតាងថ្មី” ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ (E5/10/2) និង “សេចក្តីសម្រេចស្តីពីភាយន្តរបស់ទាហានវៀតណាម ដែលដាក់ដោយសហព្រះរាជអាជ្ញា និងសេចក្តីសម្រេចស្តីពីសាក្សី CP/3/3/2 និង CP3/3/3’, ចុះថ្ងៃទី ២៩ ខែឬកក្កដា ឆ្នាំ ២០០៩ (E5/10/5))” ។ មេធាវីការពាររក្សាសិទ្ធិដាក់បន្ថែម និងប្រើឯកសារនានា (រួមទាំងរូបភាព និងវីដេអូ) នៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមិនបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារបឋមលើកទីបីឡើយ ។ មេធាវីការ

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១១

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

---

ពារក្តីទទួលបានលិបិក្រមនៃបណ្ណសាររបស់មជ្ឈមណ្ឌលនេះជាភាសាបារាំង និង ភាសាអង់គ្លេស ។ ភាសាធ្វើការរបស់ក្រុមមេធាវីការពារក្តី គឺភាសាអង់គ្លេស និងភាសាខ្មែរ ។ មកដល់ត្រឹមថ្ងៃទី១២ខែមេសា ឆ្នាំ២០១១នេះមេធាវីការពារក្តីបានពិនិត្យចប់សព្វគ្រប់នៃលិបិក្រមជាភាសាអង់គ្លេសរបស់មជ្ឈមណ្ឌលបូផាណា ។ មេធាវីការពារក្តីយល់ថាបុគ្គលរបស់មជ្ឈមណ្ឌលបូផាណាប្រើភាសាបារាំងនៅពេលពួកគេប្រើភាសាបរទេសនោះ ។ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១១ លិបិក្រមជាភាសាបារាំងនៃបណ្ណសាររបស់មជ្ឈមណ្ឌលបូផាណាមានឯកសារចំនួន ២១៧ ឯកសារ ច្រើនជាលិបិក្រមជាភាសាអង់គ្លេស ។